01200346

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 02 / 2016
ម៉ោង (Time/Heure) : 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

E386

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ជូនចំពោះ៖** **គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **ពេលវេលាដែលអង្គជំនុំជម្រះសាលាដំបូងមិនធ្វើសវនាការក្នុងឆ្នាំ ២០១៦**

1. ដើម្បីជួយសម្រួលដល់ការរៀបចំផែនការការងារ អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងទៅភាគីអំពីពេលវេលាដែលអង្គជំនុំជម្រះមិនធ្វើសវនាការក្នុងឆ្នាំ ២០១៦ ដែលមានដូចខាងក្រោមនេះ៖

| | |
|---|---|
| ថ្ងៃទី ១១ - ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ | (ពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ) |
| ថ្ងៃទី ១៣ - ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៦ | (ពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ នរោត្តម សីហមុនី, ពិធីបុណ្យវិសាខបូជា) |
| ថ្ងៃទី ០៤ - ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦ | (ការឈប់សម្រាកពាក់កណ្ដាលឆ្នាំ) |
| ថ្ងៃទី ២៦ - ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ | (ពិធីបុណ្យភ្ជុំបិណ្ឌ) |
| ថ្ងៃទី ១៤ - ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ | (ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែ) |
| ថ្ងៃទី ១៩ - ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ | (បុណ្យណូអែល/បុណ្យចូលឆ្នាំសកល) |

2. ពេលវេលាកំណត់សម្រាប់ការដាក់ឯកសារត្រូវបន្តរាប់នៅក្នុងអំឡុងពេលផ្អាកមិនធ្វើសវនាការទាំងនេះ។

3. ទោះបីជាពេលវេលានៃការផ្អាកមិនធ្វើសវនាការខាងលើនេះភាគច្រើនត្រូវចំនឹងថ្ងៃឈប់សម្រាកផ្លូវការរបស់ជាតិ និង អន្តរជាតិក៏ដោយ ក៏អង្គជំនុំជម្រះនឹងផ្អាកមិនធ្វើសវនាការផងដែរនៅថ្ងៃឈប់សម្រាកផ្លូវការមួយចំនួនតូចទៀត ដែលជាថ្ងៃឈប់សម្រាកផ្លូវការកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។ កាលបរិច្ឆេទនៃថ្ងៃឈប់សម្រាកបន្ថែមទៀតរបស់ អ.វ.ត.ក នេះ ត្រូវបានការិយាល័យរដ្ឋបាលផ្ញើជូនទៅភាគី នៅក្នុងសេចក្តីជូនដំណឹងរបស់ខ្លួនដែលមានចំណងជើងថា "ថ្ងៃឈប់សម្រាកផ្លូវការសម្រាប់ឆ្នាំ ២០១៦" ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលភ្ជាប់មកជាមួយសម្រាប់ជាឯកសារយោង។

4. អង្គជំនុំជម្រះសូមបញ្ជាក់ថា ថ្ងៃផ្អាកមិនធ្វើសវនាការមិនមែនជាថ្ងៃឈប់សម្រាកឡើយ ប៉ុន្តែគ្រាន់តែជាថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងផ្អាកមិនធ្វើសវនាការក្នុងសំណុំរឿង ០០២/០២ តែប៉ុណ្ណោះ។ ក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះនឹងធ្វើការងារពាក់ព័ន្ធនឹងសេចក្តីសម្រេចនានា និងរៀបចំផែនការ សម្រាប់ដំណាក់កាលសវនាការបន្តបន្ទាប់ទៀត។ រយៈពេលផ្អាកមិនធ្វើសវនាការនេះ ក៏មានសារៈសំខាន់ចាំបាច់ផងដែរ សម្រាប់ការកោះប្រជុំគណៈកម្មាធិការរដ្ឋបាលតុលាការ និងកិច្ចប្រជុំពេញអង្គ ក្នុងករណីចាំបាច់។